ព្រឹត្តិបត្រព័ត៌មាន

# ការប្រែប្រួល អាកាសធាតុ

# ៥

នាយកដ្ឋានប្រែប្រួលអាកាសធាតុ
អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព

ខែមេសា-មិថុនា
ឆ្នាំ២០១៦

## គោលនយោបាយប្រែប្រួលអាកាសធាតុ និងការអនុវត្ត

### ក្របខណ្ឌជាតិសម្រាប់ត្រួតពិនិត្យ និងវាយតម្លៃការប្រែប្រួលអាកាសធាតុនាពេលបច្ចុប្បន្ន

អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព(អ.ក.អ.ច.) កាលពីថ្ងៃទី៧ ខែមេសា ឆ្នាំ២០១៦ បានធ្វើការផ្សព្វផ្សាយអំពីក្របខណ្ឌជាតិសម្រាប់ត្រួតពិនិត្យ និងវាយតម្លៃការប្រែប្រួលអាកាសធាតុ។ ក្របខណ្ឌនេះ ត្រូវបានរៀបចំឡើង ដើម្បីឱ្យកម្ពុជាអាចតាមដាននូវវឌ្ឍនភាពនៃការអនុវត្តយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ និងអាចជួយឱ្យមានការស្វែងយល់អំពីការវិនិយោគដែលបាននិងកំពុងអនុវត្តទៅលើផ្នែកបន្សាំ និងកាត់បន្ថយសម្រាប់រួមចំណែកដល់ការបង្កើនភាពធន់របស់ប្រទេស និងការកាត់បន្ថយប្រពលភាពកាបូននៃសេដ្ឋកិច្ច។

ក្របខណ្ឌសម្រាប់ត្រួតពិនិត្យ និងវាយតម្លៃរបស់កម្ពុជា គឺជាលទ្ធផលនៃកិច្ចខិតខំប្រឹងប្រែងជាច្រើនឆ្នាំ ដោយគិតចាប់ពីឆ្នាំ២០១៣មក នាយកដ្ឋានប្រែប្រួលអាកាសធាតុ(ន.ប.អ.)នៃ អ.ក.អ.ច. បានធ្វើការយ៉ាងជិតស្និទ្ធជាមួយវិទ្យាស្ថានអន្តរជាតិសម្រាប់បរិស្ថាន និងអភិវឌ្ឍន៍ ព្រមទាំងបណ្ដាស្ថាប័នពាក់ព័ន្ធជាច្រើន ដើម្បីអភិវឌ្ឍ និងសាកល្បងក្របខណ្ឌថ្នាក់ជាតិនេះ ក៏ដូចជាសូចនាករនានា។




*សូចនាករចំនួន៥សម្រាប់វាស់វែងការត្រៀមស្ថាប័ន*




*សន្ទស្សន៍ភាពងាយរងគ្រោះនឹងការប្រែប្រួលអាកាសធាតុ ឆ្នាំ២០១៤*

*បន្តទៅទំព័រទី២*

## កិច្ចចរចាអន្តរជាតិស្ដីពីអាកាសធាតុ

### វឌ្ឍនភាពបន្ទាប់ពីកិច្ចព្រមព្រៀងទីក្រុងប៉ារីស: កិច្ចចរចាអាកាសធាតុទីក្រុងបោនខែឧសភា

សន្និសីទសហប្រជាជាតិស្ដីពីការប្រែប្រួលអាកាសធាតុនៅទីក្រុងបោន ប្រទេសអាល្លឺម៉ង់ ដែលបានប្រារព្ធក្នុងខែឧសភា គឺជាជំហានថ្មីមួយបន្ទាប់ពីកិច្ចព្រមព្រៀងទីក្រុងប៉ារីសដែលបានឯកភាពកាលពីខែធ្នូ ឆ្នាំ២០១៥។ សន្និសីទនេះមានប្រតិភូតំណាងរដ្ឋាភិបាលសរុបជាង ១៩០០នាក់ មកពី១៩១រដ្ឋភាគីនៃអនុសញ្ញា អ្នកសង្កេតការណ៍ ១៥០០នាក់ និងសារព័ត៌មានប្រមាណ ១០០នាក់។ ប្រតិភូកម្ពុជាចំនួន៥រូប រួមមានពីអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ២រូប រដ្ឋបាលព្រៃឈើនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ២រូប និងក្រសួងកិច្ចការនារី ១រូប។ សន្និសីទសហប្រជាជាតិនេះរួមមាន កិច្ចប្រជុំលើកទី៤៤នៃក្រុមប្រឹក្សាផ្ដល់យោបល់សម្រាប់អនុវត្តអនុសញ្ញា(SBI44), កិច្ចប្រជុំលើកទី៤៤នៃក្រុមប្រឹក្សាផ្ដល់យោបល់សម្រាប់វិទ្យាសាស្ត្រនិងបច្ចេកវិទ្យា(SBSTA44), និងកិច្ចប្រជុំលើកទី១នៃក្រុមការងារបណ្ដោះអាសន្នកិច្ចព្រមព្រៀងទីក្រុងប៉ារីស(APA)។

លទ្ធផលសម្រេចបានពីកិច្ចប្រជុំពេញអង្គនៃអង្គសន្និសីទនេះរួមមាន:

*បន្តទៅទំព័រទី៣*

## មាតិកាព័ត៌មាន

**គោលនយោបាយប្រែប្រួលអាកាសធាតុ និងការអនុវត្ត**
- ក្របខណ្ឌជាតិសម្រាប់ត្រួតពិនិត្យ និងវាយតម្លៃការប្រែប្រួលអាកាសធាតុនាពេលបច្ចុប្បន្ន......... ១
- ការកសាងសមត្ថភាពសម្រាប់រៀបចំផែនការអភិវឌ្ឍន៍ភាពធន់នឹងអាកាសធាតុ: សមិទ្ធផលសំខាន់ៗទទួលបាន.................................. ២
- ការចូលរួមចំណែករបស់វិស័យឯកជនក្នុងការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុនៅកម្ពុជា........................................... ៣

**កិច្ចចរចាអន្តរជាតិស្ដីពីអាកាសធាតុ**
- វឌ្ឍនភាពបន្ទាប់ពីកិច្ចព្រមព្រៀងទីក្រុងប៉ារីស: កិច្ចចរចាអាកាសធាតុទីក្រុងបោនខែឧសភា...... ១

**សម្លេងពីមូលដ្ឋាន** ........................................ ៤
**ឯកសារបោះពុម្ពផ្សាយថ្មីៗ**.................................. ៦
**ការចេញផ្សាយបន្ទាប់**....................................... ៦
**ឯកសារបោះពុម្ពផ្សាយនាពេលខាងមុខ**................. ៦
**ព្រឹត្តិការណ៍សំខាន់ៗនាពេលខាងមុខ**.................. ៦

### ចំណាប់អារម្មណ៍របស់និពន្ធនាយក

*សូមគោរពប្រិយមិត្តអ្នកអាន យើងខ្ញុំសូមស្វាគមន៍ចំពោះការអានព្រឹត្តិបត្រព័ត៌មានការប្រែប្រួលអាកាសធាតុ លេខ៥ ឆ្នាំ២០១៦។ ព្រឹត្តិបត្រព័ត៌មាននេះនឹងចេញផ្សាយរៀងរាល់ត្រីមាស ដើម្បីឆ្លុះបញ្ចាំងពីការអភិវឌ្ឍគោលនយោបាយអាកាសធាតុថ្មីៗនៅកម្ពុជា ព្រមទាំងបច្ចុប្បន្នភាពការងារជាច្រើនដែលអនុវត្តក្រោមអណត្តិនាយកដ្ឋានប្រែប្រួលអាកាសធាតុនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព។ ដោយឡែកក្នុងត្រីមាសទី២ និងទី៤នៃឆ្នាំនីមួយៗ យើងនឹងបន្ថែមការចែករំលែកបទពិសោធន៍ការងារសំខាន់ៗដែលអនុវត្តដោយអង្គការដៃគូ និងសហគមន៍នានាក្នុងការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។ យើងខ្ញុំសង្ឃឹមថា ប្រិយមិត្តអ្នកអាននឹងផ្ដល់ជាធាតុចូលដូចជាការផ្ដល់មេរៀនល្អៗ និងករណីសិក្សានានាដែលនាំឱ្យព្រឹត្តិបត្រនេះជោគជ័យ៕*

### ក្រុមការងាររៀបចំ និងត្រួតពិនិត្យ

ព្រឹត្តិបត្រព័ត៌មាននេះ ត្រូវបានរៀបចំ កែសម្រួល និងផលិតដោយនាយកដ្ឋានប្រែប្រួលអាកាសធាតុនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ដោយមានជំនួយបច្ចេកទេសពីកម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា៕

# គោលនយោបាយប្រែប្រួលអាកាសធាតុនិងការអនុវត្ត

## ក្របខណ្ឌជាតិសម្រាប់ត្រួតពិនិត្យ និងវាយតម្លៃការប្រែប្រួល...

*បន្តពីទំព័រទី១*

រហូតមកទល់បច្ចុប្បន្ន ក្របខណ្ឌជាតិនេះមានសូចនាករស្នូលថ្នាក់ជាតិសរុបចំនួន៨ ដោយនៅតាមក្រសួង ស្ថាប័នពាក់ព័ន្ធដែលត្រូវបង្កើត នឹងមានសូចនាករចំនួន២ឬ៣បន្ថែមសម្រាប់ដាក់បញ្ចូលទៅក្នុងវិស័យណាមួយក្នុងការត្រួតពិនិត្យ និងវាយតម្លៃការប្រែប្រួលអាកាសធាតុរបស់វិស័យនោះ។

ក្របខណ្ឌជាតិសម្រាប់ត្រួតពិនិត្យ និងវាយតម្លៃការប្រែប្រួលអាកាសធាតុ ត្រូវបានប្រើប្រាស់វិធីសាស្ត្រភ្លោះ ដោយវាស់វែងទាំង:

- *លទ្ធភាពស្ថាប័នថ្នាក់ជាតិក្នុងការគ្រប់គ្រងហានិភ័យអាកាសធាតុ* តាមរយៈសូចនាករត្រៀមផ្នែកស្ថាប័នចំនួន៥ គឺ ១)ស្ថានភាពនៃគោលនយោបាយ និងយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុ ២)ស្ថានភាពនៃការបញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងផែនការអភិវឌ្ឍន៍ ៣)ស្ថានភាពនៃកិច្ចសម្របសម្រួល ៤)ស្ថានភាពនៃព័ត៌មានអាកាសធាតុ និង៥)ស្ថានភាពនៃការបញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងហិរញ្ញប្បទាន។
- *ភាពជោគជ័យនៃកិច្ចអន្តរាគមន៍អាកាសធាតុដែលបាននិងកំពុងអនុវត្តក្នុងការកាត់បន្ថយភាពងាយរងគ្រោះ ឬបន្ទាបការបញ្ចេញកាបូន* តាមរយៈសូចនាករនៃផលប៉ះពាល់ចំនួន៣ គឺ ១)ភាគរយនៃឃុំដែលងាយរងគ្រោះទៅនឹងការប្រែប្រួលអាកាសធាតុ ២)ចំនួនគ្រួសារដែលរងឥទ្ធិពលដោយទឹកជំនន់ ខ្យល់ព្យុះ និងភាពរាំងស្ងួត និង៣)ការបញ្ចេញឧស្ម័នផ្ទះកញ្ចក់។



ឯកឧត្តម ទិន ពន្លក អគ្គលេខាធិការក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ប្រកាសផ្សព្វផ្សាយក្របខណ្ឌជាតិសម្រាប់ត្រួតពិនិត្យនិងវាយតម្លៃការប្រែប្រួលអាកាសធាតុ នៅរាជធានីភ្នំពេញ ថ្ងៃទី៧ ខែមេសា ឆ្នាំ២០១៦

ន.ប.អ. កំពុងលើកទឹកចិត្តដល់ក្រសួងស្ថាប័នឱ្យរៀបចំក្របខណ្ឌតាមដាន និងវាយតម្លៃរបស់ខ្លួនដោយផ្អែកលើវិធីសាស្ត្រភ្លោះនេះ ដើម្បីសម្រេចបាននូវការតាមដានវឌ្ឍនភាពការងារឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុតាមវិស័យរបស់ខ្លួន។ រហូតមកបច្ចុប្បន្ន មានក្រសួងចំនួនបីរួមមាន ក្រសួងសាធារណការ និងដឹកជញ្ជូន ក្រសួងសុខាភិបាល និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានបង្កើតក្របខណ្ឌតាមវិស័យរបស់ខ្លួនរួចហើយ៕

## ការកសាងសមត្ថភាពសម្រាប់រៀបចំផែនការអភិវឌ្ឍន៍ភាពធន់នឹងអាកាសធាតុ: សមិទ្ធផលសំខាន់ៗទទួលបាន

នាយកដ្ឋានប្រែប្រួលអាកាសធាតុ(ន.ប.អ)នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ដោយមានជំនួយបច្ចេកទេសពីកម្មវិធីបញ្ជ្រាបភាពធន់នឹងអាកាសធាតុទៅក្នុងការរៀបចំផែនការអភិវឌ្ឍន៍(MCRDP) កំពុងចាប់ផ្តើមដាក់បញ្ចូលភាពធន់នឹងអាកាសធាតុទៅក្នុងការរៀបចំកម្មវិធី និងគោលនយោបាយរបស់វិស័យសំខាន់ៗដូចជា វិស័យកសិកម្ម ការគ្រប់គ្រងធនធានទឹក ការអភិវឌ្ឍទីក្រុង និងការដឹកជញ្ជូន។

ក្រុមការងារបន្សាំនៃកម្មវិធីយុទ្ធសាស្ត្រសម្រាប់ភាពធន់នឹងអាកាសធាតុដែលបង្កើតឡើងដោយមានសមាសភាពពីក្រសួងពាក់ព័ន្ធនឹងគម្រោង បានសម្រេចសមិទ្ធផលសំខាន់ៗ ដូចខាងក្រោម:

- *ណែនាំឧបករណ៍គ្រប់គ្រងហានិភ័យប្រែប្រួលអាកាសធាតុតាមវិស័យដែលមានលក្ខណៈសមស្របសម្រាប់កម្ពុជា:* សមាជិកក្រុមការងារបន្សាំនឹងការប្រែប្រួលអាកាសធាតុ បានបង្កើនជំនាញរបស់ខ្លួនក្នុងការប្រើប្រាស់ឧបករណ៍រៀបចំផែនការនានាដែលធន់នឹងអាកាសធាតុ និងមានសមត្ថភាពដាក់បញ្ចូលវិធានការបន្សាំទៅក្នុងកម្មវិធី និងគោលនយោបាយរបស់វិស័យជាច្រើន។ ដើម្បីពង្រឹងចំណេះដឹងនេះ មន្ត្រីរដ្ឋាភិបាលចំនួន៣៥នាក់ បានទទួលការបណ្តុះបណ្តាលស៊ីជម្រៅអំពីឧបករណ៍កំណត់ហានិភ័យអាកាសធាតុ កាលពីខែមេសា ឆ្នាំ២០១៦។
- *ចងក្រងវិធានការបន្សាំសម្រាប់ចែករំលែកចំណេះដឹង:* សមាជិកក្រុមការងារបន្សាំបានយកចំណេះដឹងដែលទទួលបានពីវគ្គខាងលើមកកំណត់ និងចងក្រងបទពិសោធន៍បន្សាំដែលមានអាទិភាព នៅក្នុងខេត្តដែលងាយរងគ្រោះបំផុតនៅកម្ពុជាដូចជា ខេត្តបាត់ដំបង កោះកុង កំពង់ធំ ត្បូងឃ្មុំ មណ្ឌលគីរី ពោធិ៍សាត់ ព្រៃវែង និងកំពង់ឆ្នាំង។ ដោយផ្អែកលើលទ្ធផលនៃការវាយតម្លៃនៅមូលដ្ឋានទាំងនេះ ក្រុមការងារបច្ចេកទេសគម្រោងMCRDP និងក្រុមការងារបន្សាំ បានចងក្រងសេចក្តីព្រាងករណីសិក្សាអំពីការអនុវត្តបន្សាំសម្រាប់វិស័យកសិកម្ម ការគ្រប់គ្រងធនធានទឹក ការអភិវឌ្ឍទីក្រុង និងការដឹកជញ្ជូន។ នឹងមានការផលិតវីដេអូឯកសារមួយសម្រាប់ផ្សព្វផ្សាយអំពីកិច្ចប្រឹងប្រែងទាំងនេះ និងកិច្ចប្រឹងប្រែងលើបន្សាំផ្សេងៗ។



ក្រុមការងារបន្សាំនឹងការប្រែប្រួលអាកាសធាតុរៀបចំទស្សនកិច្ចសិក្សាអំពីការកំណត់លទ្ធភាពសម្រាប់រៀបចំសំណើគម្រោងបន្សាំនឹងការប្រែប្រួលអាកាសធាតុ នៅខេត្តពោធិ៍សាត់ ខែមីនា ឆ្នាំ២០១៦

- *កំពុងរៀបចំសិក្សាលម្អិតអំពីលទ្ធភាពគម្រោងបន្សាំនឹងការប្រែប្រួលអាកាសធាតុ:* តាមរយៈការប្រើប្រាស់ឧបករណ៍សិក្សារៀនសូត្រ ន.ប.អ. ដែលគាំទ្រដោយគម្រោងMCRDP កំពុងសហការជាមួយក្រសួងសំខាន់ៗក្នុងការសិក្សាលម្អិតទៅលើលទ្ធភាពនៃការលើកសំណើគម្រោង។ វិស័យនីមួយៗនឹងចាត់អាទិភាពបន្សាំចំនួន១ឬ២ក្នុងចំណោមករណីសិក្សាទាំងនោះ ដើម្បីបន្តរៀបចំការសិក្សាលម្អិត។ ក្រុមជំនួយបច្ចេកទេសកំពុងសហការជាមួយក្រសួងនីមួយៗដើម្បីកំណត់យន្តការហិរញ្ញប្បទានបន្សាំដែលពាក់ព័ន្ធ ដែលអាចឱ្យក្រសួងទាំងនោះប្រែក្លាយសំណើគម្រោងរបស់ខ្លួនទៅជាសកម្មភាពច្បាស់លាស់សម្រាប់ភាពធន់នឹងអាកាសធាតុ។ សម្រាប់ព័ត៌មានលម្អិតអំពីគម្រោង: www.spcrcambodia.org៕

## ការចូលរួមចំណែករបស់វិស័យឯកជនក្នុងការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុនៅកម្ពុជា

តួនាទីរបស់វិស័យឯកជន និងអង្គការមិនមែនរដ្ឋាភិបាលនៅក្នុងផ្នែកហិរញ្ញវត្ថុអាកាសធាតុ កាន់តែមានសារៈសំខាន់ ដោយសារប្រទេសកម្ពុជាមានការអភិវឌ្ឍ ដែលតម្រូវឱ្យវិស័យឯកជនធ្វើការវិនិយោគលើការងារកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ ហើយអង្គការមិនមែនរដ្ឋាភិបាលធ្វើការបង្កើនការយល់ដឹងជាសាធារណៈ និងបញ្ចុះបញ្ចូលឱ្យមានការទទួលខុសត្រូវផ្នែកសង្គម។

ការសិក្សាស្តីពី «ការចូលរួមចំណែករបស់វិស័យឯកជនក្នុងការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុនៅកម្ពុជា» ត្រូវបានរៀបចំដោយមានសំណើពីនាយកដ្ឋានប្រែប្រួលអាកាសធាតុនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព និងដោយមានការគាំទ្រពីកម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា។

ការសិក្សាមួយនេះ បានពិនិត្យទៅលើការងារវិនិយោគជាច្រើនរបស់ក្រុមហ៊ុនចំនួន៦៥ និងកំណត់បាននូវកម្មវិធី និងសកម្មភាពពាក់ព័ន្ធអាកាសធាតុដែលរួមមាន: កសិកម្មឆ្លាតខាងអាកាសធាតុ, ការស្តារព្រៃឈើឡើងវិញ កសិ-ឧស្សាហកម្ម កសិ-ពាណិជ្ជកម្មប្រកបដោយនិរន្តរភាព និងការបង់សេវាកម្មប្រព័ន្ធអេកូឡូស៊ី, ការស្តារព្រៃកោងកាង ការអភិរក្សដី និងវារីវប្បកម្មប្រកបដោយនិរន្តរភាព, កិច្ចអន្តរាគមន៍ពាក់ព័ន្ធអាកាសធាតុក្នុងវិស័យរោងចក្រសំដៅធានាបាននូវនិរន្តរភាពនៃខ្សែសង្វាក់ផ្គត់ផ្គង់ និងការសម្របតាមស្តង់ដារគុណភាពបរិស្ថាន, ការប្រើប្រាស់ថាមពល និងប្រសិទ្ធភាពថាមពលរួមមាន ថាមពលជីវឧស្ម័ន ថាមពលពន្លឺព្រះអាទិត្យ វារីអគ្គិសនី, ការគ្រប់គ្រងសំណល់រឹងរាវ តាមគោលការណ៍ 3Rs, អគារបៃតង និងក្រម/ច្បាប់សាងសង់ដែលបញ្ចេញកាបូនទាប, ការដឹកជញ្ជូនប្រកបដោយនិរន្តរភាព, អេកូទេសចរណ៍/សណ្ឋាគារបៃតង, ការប្រើប្រាស់តាមគ្រួសារដោយរួមបញ្ចូលទាំងការចម្អិន ការបំភ្លឺ ការដឹកជញ្ជូនឯកជន។ល។


*ម្ចាស់អាជីវកម្មបញ្ចូលចំណីសត្វទៅក្នុងម៉ាស៊ីនកិនចំណីសត្វនៅខេត្តតាកែវ*

ការសិក្សាក៏បានបង្ហាញពីបញ្ហាប្រឈមចម្បង២ដែលវិស័យឯកជនជួបប្រទះក្នុងការវិនិយោគបៃតង ដូចជា: កង្វះព័ត៌មានឬគោលការណ៍ណែនាំអំពីការច្នៃប្រឌិត និងបច្ចេកវិទ្យាបញ្ចេញកាបូនទាប, ពិបាកក្នុងការស្វែងរកការគាំទ្រផ្នែកថវិកាសម្រាប់គម្រោងដែលមានមេត្រីភាពនឹងអាកាសធាតុ, ការទទួលនូវដំណោះស្រាយផ្នែកបច្ចេកទេសនៅមានកម្រិតទាប, កង្វះខាតធនធានមនុស្សដែលមានសមត្ថភាព និងជំនាញ, កង្វះខាតគោលនយោបាយគាំទ្រសមស្រប។

បន្ទាប់ពីមានកិច្ចពិគ្រោះយោបល់ជាច្រើនលើកជាមួយវិស័យឯកជន និងដៃគូអភិវឌ្ឍន៍ផ្សេងៗក្នុងខែមីនា ឆ្នាំ២០១៦ ការសិក្សាបានផ្តល់អនុសាសន៍សំខាន់ៗចំនួន២០ចំណុចជូនដល់រាជរដ្ឋាភិបាល ដើម្បីលើកកម្ពស់ការវិនិយោគដែលឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ៕

# កិច្ចចរចាអន្តរជាតិស្តីពីអាកាសធាតុ

## វឌ្ឍនភាពបន្ទាប់ពីកិច្ចព្រមព្រៀងប៉ារីស: កិច្ចសន្ទនាអាកាសធាតុ...

*បន្តពីទំព័រទី១*

- *SBI44 បានអនុម័តសេចក្តីសន្និដ្ឋានជាច្រើនទាក់ទងនឹងការងារអនុវត្តទៀងទាត់របស់ខ្លួន* ដូចជា យន្តការនានាដែលស្ថិតនៅក្រោមពិធីសារក្យូតូ ការកសាងសមត្ថភាព យេនឌ័រ និងផែនការជាតិបន្សាំ។ SBI44 ក៏បានចាប់ផ្តើមការងារពាក់ព័ន្ធនឹងអាណត្តិរបស់ខ្លួននៅក្រោមកិច្ចព្រមព្រៀងទីក្រុងប៉ារីស ដោយចាប់ផ្តើមពីការរៀបចំទម្រង់បែបបទ និងនីតិវិធីនៃការចុះបញ្ជីជាសាធារណៈសម្រាប់ការរួមចំណែកថ្នាក់ជាតិ( NDCs ) និងការងារបន្សាំ។ មានការសន្និដ្ឋានខុសៗគ្នាទៅលើNDCs ដោយប្រទេសអភិវឌ្ឍន៍គិតតែលើការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ ចំណែកប្រទេសកំពុងអភិវឌ្ឍន៍យល់ថាគឺត្រូវរួមបញ្ចូលទាំងបន្សាំ និងមធ្យោបាយអនុវត្តផងដែរ។
- *SBSTA44 បានអនុម័តនូវសេចក្តីសន្និដ្ឋានជាច្រើន* រួមមាននីតិវិធីនៅក្រោមអនុសញ្ញា និងពិធីសារក្យូតូ ព្រមទាំងកម្មវិធីការងារទីក្រុងណៃរ៉ូប៊ីទៅលើផលប៉ះពាល់ ភាពងាយរងគ្រោះ និងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ។ SBSTA44 ក៏បានចាប់ផ្តើមពិចារណាពីបញ្ហានានានៅក្រោមកិច្ចព្រមព្រៀងទីក្រុងប៉ារីស រួមមានក្របខណ្ឌបច្ចេកវិទ្យា និងទម្រង់បែបបទនិងនីតិវិធីនានាសម្រាប់មាត្រាទី៦នៃកិច្ចព្រមព្រៀងទីក្រុងប៉ារីស( វិធីសាស្ត្រកិច្ចសហប្រតិបត្តិការ )។
- *APA បានអនុម័តលើរបៀបវារៈកម្មវិធីការងាររបស់ខ្លួនទៅលើគោលដៅនិងទិដ្ឋភាពនានានៃការអនុវត្តNDCs* ដែលគ្របដណ្តប់លើការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ការងារបន្សាំ និងមធ្យោបាយនៃការអនុវត្តNDCs និងបានអនុម័តសេចក្តីសន្និដ្ឋានរបស់ខ្លួនសម្រាប់ការងារបន្ថែមទៀត។



*ប្រតិភូនៃបណ្តាប្រទេសចូលរួមក្រុមការងារបណ្តោះអាសន្នកិច្ចព្រមព្រៀងទីក្រុងប៉ារីស នៅទីក្រុងបោន ប្រទេសអាល្លឺម៉ង់ ខែឧសភា ឆ្នាំ២០១៦*
©IISD

សន្និសីទនេះ បានអំពាវនាវឱ្យភាគីទាំងអស់ចុះហត្ថលេខាទទួលស្គាល់លើវិសោធនកម្មទីក្រុងដូហាសម្រាប់អនុវត្តពិធីសារក្យូតូដំណាក់កាលទី២។ កម្ពុជាបានចុះហត្ថលេខាលើលិខិតូបករណ៍យល់ព្រមលើវិសោធនកម្មដូហានៃពិធីសារក្យូតូ នៅថ្ងៃទី៧ ខែតុលា ឆ្នាំ២០១៥ ដែលអនុញ្ញាតឱ្យប្រទេសកម្ពុជាចូលរួមអនុវត្តគម្រោងនានាក្រោមយន្តការអភិវឌ្ឍន៍ស្អាតនៃពិធីសារក្យូតូ ក្នុងរវាងឆ្នាំ២០១៣-២០២០។

វិសោធនកម្មទីក្រុងដូហាមានរយៈពេលរហូតដល់មុនឆ្នាំ២០២០ ដែលបានចែងពីឧបករណ៍សំខាន់ៗនៅក្នុងកិច្ចខិតខំប្រឹងប្រែងកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ជារួម ដើម្បីរក្សាកំណើនសីតុណ្ហភាពមធ្យមសកលនៅក្រោម២អង្សាសេធៀបនឹងកម្រិតមុនបដិវត្តឧស្សាហកម្ម និងនៅមុនពេលកិច្ចព្រមព្រៀងទីក្រុងប៉ារីសត្រូវបានចូលជាធរមាន។ នៅត្រឹមថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ មានតែប្រទេសចំនួន៦៦ប៉ុណ្ណោះ ក្នុងចំណោមប្រទេសទាំង១៩២នៃពិធីសារក្យូតូ បានផ្តល់សច្ចាប័នលើវិសោធនកម្មទីក្រុងដូហា៕

# សម្លេងពីមូលដ្ឋាន

## ការផ្លាស់ប្តូរពូជស្រូវថ្មីនិងបច្ចេកទេសដាំដុះ

លោក ដោ ជាកសិករម្នាក់មានអាយុ៧៥ឆ្នាំ រស់នៅក្នុងភូមិព្រីង ឃុំក្រាំងស្វាយ ស្រុកព្រះស្តេច ខេត្តព្រៃវែង តាំងពីឆ្នាំ១៩៦៥។ គាត់មានកូនប្រាំពីរនាក់ និងរស់នៅក្នុងផ្ទះឈើតូចមួយនៅលើផ្លូវជាតិលេខ១១។ គាត់មានដីចំនួនប្រាំកន្លែង ធ្វើស្រែ និងដាំបន្លែដើម្បីផ្គត់ផ្គង់ជីវភាព ប៉ុន្តែការដាំដុះនោះបានតែក្នុងរដូវវស្សាប៉ុណ្ណោះដោយសារគ្មានប្រភពទឹកនៅរដូវប្រាំង។

គាត់បានកត់សម្គាល់ថាមានការប្រែប្រួលជាច្រើននៅក្នុងភូមិរបស់គាត់ដូចជា ប្រជាជនធ្លាប់តែមានទឹកសម្រាប់ស្រោចស្រពដំណាំគ្រប់គ្រាន់ និងទាន់ពេលវេលា និងអាចទទួលបានទិន្នផលខ្ពស់ដោយមិនចាំបាច់ប្រើជីគីមីច្រើនឡើយ។ ប៉ុន្តែឥឡូវនេះ ដំណាំមិនអាចរីកលូតលាស់បានល្អទេ ដោយសារភ្លៀងមិនគ្រប់គ្រាន់។ គាត់បានឮពីអ្នកជិតខាង និងតាមរយៈវិទ្យុថាអាកាសធាតុកំពុងប្រែប្រួល ហើយថាកសិករចាំបាច់ត្រូវផ្លាស់ប្តូររបៀបធ្វើស្រែចំការ។


លោកដោ និងក្រុមគ្រួសាររបស់គាត់ដឹកជញ្ជូនពូជស្រូវទៅកាន់ស្រែរបស់គាត់

ឥឡូវនេះ លោក ដោ បានដាំដុះប្រភេទពូជស្រូវស្រាលជំនួសប្រភេទពូជស្រូវធ្ងន់ដែលធ្លាប់ដាំពីមុន ហើយគាត់ក៏បានប្រើបច្ចេកទេសដាំដុះផ្សេងដូចជា ពីការដាំបែបដកស្ទូងទៅជាការព្រួសវិញម្តង។ គាត់បានកត់សម្គាល់ថាការសម្រេចចិត្តនេះបានធ្វើឱ្យគ្រាប់ពូជដុះកាន់តែច្រើន ហើយពូជស្រូវថ្មីនោះអាចទប់ទល់នឹងវិសមរូបអាកាសធាតុបច្ចុប្បន្នកាន់តែប្រសើរ ជាពិសេសការធ្លាក់ភ្លៀងមិនទៀងទាត់ និងភាពរាំងស្ងួតដែលអូសបន្លាយ។ មិនតែប៉ុណ្ណោះ វាអាចលក់បានថ្លៃក្នុងទីផ្សារ ហើយមិនចាំបាច់ចំណាយពេលច្រើនក្នុងការដាំដុះដោយសារវដ្តផលិតកម្មមានរយៈពេលតែបីខែ ជំនួសពីការដាំដុះពូជស្រូវដែលធ្វើតាមទម្លាប់ប្រពៃណីដែលមានរយៈពេលពី៥ទៅ៦ខែ។

លោក ដោ បានកំពុងស្វែងរកវិធីដែលអាចបន្សុំាទៅនឹងការផ្លាស់ប្តូររបបទឹកភ្លៀងបានប្រសើរជាងមុន។ ឆ្នាំនេះ ដោយសារភ្លៀងធ្លាក់យឺត គាត់បានសម្រេចចិត្តប្រើយុទ្ធសាស្ត្រថ្មីមួយផ្សេងទៀត ដោយការព្រួសពូជ បន្ទាប់មកភ្ជួរលើពូជស្រូវប្រាំងដោយមិនរង់ចាំទឹកភ្លៀងឡើយ ដែលនេះជាគំនិតទទួលបានពីអ្នកភូមិដែលធ្លាប់បានសាកល្បងកាលពីរដូវវស្សាកន្លងមក។

ទោះបីជានេះជាលើកទី១ដែលគាត់ប្រើវិធីសាស្ត្រនេះក៏ដោយ ក៏គាត់គិតថាគ្មានអ្វីប្រសើរជាងសាកល្បងជម្រើសនានាដែលអាចធ្វើទៅបាន ជាជាងរង់ចាំទឹកភ្លៀង៕


លោកដោ និងអ្នកភូមិដទៃទៀតប្រមូលផលពូជស្រូវថ្មីដែលបានបន្សុំាទៅនឹងការប្រែប្រួលអាកាសធាតុ

## ការពង្រឹងសន្តិសុខស្បៀង និងបង្កើនប្រាក់ចំណូលនៅក្នុងសហគមន៍តំបន់ការពារ

សហគមន៍តំបន់ការពារធម្មជាតិជីឱកបឹងប្រិយ៍ ដែលស្ថិតនៅក្នុងខេត្តព្រះវិហារ ត្រូវបានគាំទ្រដោយគម្រោងជម្រុញភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុរបស់សហគមន៍ជនបទតំបន់ការពារធម្មជាតិនៅកម្ពុជា។ គម្រោងនេះ បានប្រើប្រាស់វិធីសាស្ត្របន្សុំាផ្អែកលើប្រព័ន្ធអេកូឡូស៊ី ក្នុងគោលបំណងកាត់បន្ថយសម្ពាធទៅលើព្រៃឈើតាមរយៈការបង្កើនសន្តិសុខស្បៀង និងបង្កើនប្រាក់ចំណូលពីព្រៃឈើសម្រាប់ប្រជាជនមូលដ្ឋានដែលពឹងអាស្រ័យលើធនធានព្រៃឈើ។ សមត្ថភាពរបស់គណៈកម្មការសហគមន៍ និងសមាជិក ក៏ត្រូវបានពង្រឹងដើម្បីបង្កើនការយល់ដឹងអំពីការប្រែប្រួលអាកាសធាតុ និងការអនុវត្តល្អៗក្នុងការដោះស្រាយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។

បន្តទៅទំព័រទី៥


ចំការបណ្តុះកូនឈើក្នុងសហគមន៍តំបន់ការពារជីឱកបឹងប្រិយ៍ ខេត្តព្រះវិហារ ខែឧសភា ២០១៥

## គម្រោងរដ្ឋាភិបាលមូលដ្ឋាន និងការប្រែប្រួលអាកាសធាតុបានបង្កើនជីវភាពប្រជាជនជាច្រើនរយគ្រួសារ

ប្រឡាយមួយខ្សែប្រវែង ១៤៥០ម៉ែត្រ ត្រូវបានស្តារឡើងវិញ ដើម្បីបម្រើសេដ្ឋកិច្ច ការដឹកជញ្ជូន និងជីវភាពប្រជាជនមូលដ្ឋាន ដែលគាំទ្រដោយគម្រោងរដ្ឋាភិបាលមូលដ្ឋាន និងការប្រែប្រួលអាកាសធាតុរបស់លេខាធិការដ្ឋានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ(គ.ជ.អ.ប.) ដែលបានផ្តល់មូលនិធិដោយកម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជាដំណាក់កាលទី១។

ប្រឡាយនេះស្ថិតនៅក្នុងឃុំត្នោតស្រុកបាទី ខេត្តតាកែវ មានភូមិចំនួន២នៅជុំវិញ ក្នុងនោះមានភូមិឈើទាល និងភូមិព្រៃជប់។ ដោយសារឃុំទាំងនោះងាយរងគ្រោះនឹងគ្រោះរាំងស្ងួត និងប្រើប្រាស់ទឹកទន្លេបានតិច ការស្តារប្រឡាយនេះបានក្លាយជាតម្រូវការអាទិភាពដំបូងនៃផែនការវិនិយោគឃុំ ដែលអាចផ្តល់ទឹកសម្រាប់ស្រែស្រូវ ដំណាំ ស្រះចិញ្ចឹមត្រី ដោយមានការគ្រប់គ្រងលំហូរទឹក។ លើសពីនេះ វាបានក្លាយជាបណ្តាញដឹកជញ្ជូនដ៏មានតម្លៃរបស់ឃុំ ដែលតភ្ជាប់ពីឃុំនេះទៅនឹងឃុំ៣ផ្សេងទៀត ពិសេសសម្រាប់ការអប់រំកុមារ និងចលនាសេដ្ឋកិច្ច។ ទីប្រឹក្សាគម្រោងប្រចាំស្រុកបាទីបានបង្ហាញថា «គម្រោងនេះពិតជាមានសារៈសំខាន់ក្នុងការកែលម្អជីវភាពសហគមន៍ ជាពិសេសប្រជាជនងាយរងគ្រោះ ដោយសារវាបានដោះស្រាយនូវតម្រូវការ និងបញ្ហាប្រឈមរបស់អ្នកភូមិពិតប្រាកដ លើកកម្ពស់



ប្រឡាយដែលបានស្តារស្ថិតក្នុងឃុំត្នោត ស្រុកបាទី ខេត្តតាកែវ, ខែឧសភា ២០១៦ ©គ.ជ.អ.ប.



គណៈកម្មការគ្រប់គ្រងទឹកពិភាក្សាអំពីអត្ថប្រយោជន៍នៃការស្តារប្រឡាយ និងអភិវឌ្ឍន៍សមត្ថភាពគណៈកម្មការ នៃខេត្តតាកែវ ខែឧសភា ឆ្នាំ២០១៦ ©គ.ជ.អ.ប.

ការចូលរួមជាបដិភាគ និងនាំឱ្យប្រជាជនបន្សាំនឹងការប្រែប្រួលអាកាសធាតុកាន់តែប្រសើរឡើង»។ មេឃុំត្នោតបានបន្ថែមថា មុននឹងគម្រោងនេះចាប់ផ្តើម ហើយមុនពេលក្រុមប្រឹក្សាឃុំទទួលវគ្គបណ្តុះបណ្តាលស្តីពីការប្រែប្រួលអាកាសធាតុ ពួកគាត់មិនដែលឃើញការស្តារប្រឡាយណាដែលអាចរួមចំណែកបង្កើនភាពធន់នៅក្នុងសហគមន៍គាត់ឡើយ ទោះបីជាវាត្រូវបានកំណត់ជាអាទិភាពមួយដោយក្រុមប្រឹក្សាឃុំក៏ដោយ។ ចាប់ពីពេលនោះមក ក្រុមប្រឹក្សាឃុំបានលើកកម្ពស់ការយល់ដឹងរបស់អ្នកភូមិក្នុងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងត្រៀមបង្ការ ដែលអាចធានាបានសមត្ថភាពស្តុកទឹក ការជីកស្រះសម្រាប់ប្រើប្រាស់តាមផ្ទះឱ្យបានគ្រប់គ្រាន់។ល។

ទោះបីជាគម្រោងដំបូងនេះត្រូវបានបញ្ចប់ ក៏ការងារនេះនៅតែបន្ត។ តាមរយៈការកៀរគរមូលនិធិឃុំដែលជាមូលនិធិសំខាន់បន្ថែមទៅលើមូលនិធិពីទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិស៊ុយអែត និងមូលនិធិអភិវឌ្ឍន៍មូលធនសហប្រជាជាតិ កិច្ចអន្តរាគមន៍បង្កើនលទ្ធភាពទទួលបានទឹករបស់សហគមន៍នេះ គឺនៅតែបន្តអនុវត្តសម្រាប់រួមចំណែកដល់ការកែលម្អជីវភាពប្រជាជនមូលដ្ឋាន៕

## ការពង្រឹងសន្តិសុខស្បៀង និងបង្កើនប្រាក់ចំណូលពនៅក្នុង...

*បន្តពីទំព័រទី៤*

ប្រជាជនមូលដ្ឋានគឺមានភាពងាយរងគ្រោះទៅនឹងព្យុះ ភ្លៀងធ្លាក់មិនប្រក្រតី ភាពរាំងស្ងួត និងសីតុណ្ហភាពក្តៅ។ ក្នុងការឆ្លើយតបទៅនឹងមហន្តរាយអាកាសធាតុទាំងនេះ សហគមន៍បានស្តារឡើងវិញនូវដីព្រៃរេចរឹលតាមរយៈការដាំដើមឈើក្នុងសហគមន៍ និងលក្ខណៈគ្រួសារ។ សហគមន៍បានដាំដើមឈើប្រមាណជាង៣៥០ដើម និងបណ្តុះកូនឈើចំនួន១៣០០០ដើម នៅថ្នាលបណ្តុះកូនឈើសហគមន៍។ ដោយមានការគាំទ្រពីគម្រោងនេះ សហគមន៍ក៏បានផ្តល់គ្រាប់ពូជបន្លែ ចបកាប់ បំពង់ទឹកសម្រាប់ដឹកអណ្តូង ពាងទឹកនិងដើមឈើហូបផ្លែ (ឧ.ដើមខ្នុរ និងស្វាយ) ដល់សមាជិករបស់ខ្លួនសម្រាប់សួនដំណាំតាមផ្ទះ។ ក្រៅពីការប្រមូលអនុផលព្រៃឈើ ប្រជាជនបានផ្លាស់ប្តូរពីកសិកម្មពនេចរទៅជាការដាំដុះដំឡូងមីជាអចិន្ត្រៃយ៍។

លោក ចាន់ ភួន សមាជិកគណៈកម្មការ និងជាអ្នកទទួលផលពីគម្រោង។ ក្រៅពីការងារសហគមន៍ គាត់បានដាំបន្លែ និងដំឡូងមី។ ការផ្តល់គ្រាប់ពូជបន្លែ ធ្វើឱ្យគាត់អាចពង្រីកសួនដំណាំ បង្កើនផលដំណាំ និងបន្ថែមប្រាក់ចំណូលសម្រាប់គ្រួសារ។ ទោះយ៉ាងណា ភាពរាំងស្ងួត និងភ្លៀងធ្លាក់មិនខុសប្រក្រតីនៅតែជាក្តីព្រួយបារម្ភរបស់គាត់ ដោយសារវានៅតែប៉ះពាល់ដល់ការដាំបន្លែនិងដំឡូងមី។ ភ្លៀងបានធ្លាក់យឺត ហើយបើទោះបីជាគាត់បានស្វែងរកការណែនាំបច្ចេកទេសថ្មីពីអ្នកជំនាញកសិកម្ម ក៏នៅតែមិនទាន់ដោះស្រាយបានទាំងស្រុង៕

✎ សូមចុះឈ្មោះជាអ្នកចូលរួមចំណែកបង្ហាញសម្លេងពីមូលដ្ឋានជាអចិន្ត្រៃយ៍ ឬមិនអចិន្ត្រៃយ៍ ដោយការផ្ញើអត្ថបទ មកសារអេឡិចត្រូនិកៈ reaksmey.neou@camclimate.org.kh

## ឯកសារបោះពុម្ពផ្សាយថ្មីៗ

១) របាយការណ៍ស្តីពីការពិនិត្យការចំណាយសាធារណៈពាក់ព័ន្ធអាកាសធាតុ ឆ្នាំ២០១៣-២០១៤, អង់គ្លេស *http://www.camclimate.org.kh/en/documents-and-media/library/category/39-financing.html*

២) ការសិក្សាលើកទីពីរស្តីពីការស្វែងយល់ទស្សនៈសាធារណជនចំពោះការប្រែប្រួលអាកាសធាតុនៅប្រទេសកម្ពុជា: ចំណេះដឹង ឥរិយាបទ និងការអនុវត្ត, ខ្មែរ និងអង់គ្លេស, *http://www.camclimate.org.kh/en/documents-and-media/library/category/139-second-study-on-understanding-public-perception-report-kap2.html*

៣) ការសិក្សាអំពីឧបករណ៍វាយតម្លៃការប្រែប្រួលអាកាសធាតុសម្រាប់ក្រសួង ស្ថាប័នតាមវិស័យនៅប្រទេសកម្ពុជា, អង់គ្លេស, *http://www.spcrcambodia.org/en/publications.php*

៤) ឯកសារសង្ខេបអំពីក្របខណ្ឌត្រួតពិនិត្យ និងវាយតម្លៃការប្រែប្រួលអាកាសធាតុ និងរបាយការណ៍សិក្សាអំពីការត្រួតពិនិត្យនិងវាយតម្លៃការប្រែប្រួលអាកាសធាតុ, អង់គ្លេស, *http://www.camclimate.org.kh/en/documents-and-media/library/category/140-climate-change-m-e-framework.html*

## ការចេញផ្សាយបន្ទាប់...



### សទ្ទានុក្រមប្រែប្រួលអាកាសធាតុភាសាខ្មែរកំពុងមានការត្រួតពិនិត្យ

សទ្ទានុក្រមប្រែប្រួលអាកាសធាតុជាភាសាខ្មែរត្រូវបានចងក្រង ដើម្បីជានាសង្គតិភាព និងភាពត្រឹមត្រូវក្នុងការប្រើប្រាស់ពាក្យបច្ចេកទេសប្រែប្រួលអាកាសធាតុ។ ក្រុមការងារសទ្ទានុក្រមដែលមានសមាសភាពជាអ្នកជំនាញមកពីនាយកដ្ឋានប្រែប្រួលអាកាសធាតុកម្ពុជា កម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុ និងកម្មវិធីយុទ្ធសាស្ត្រសម្រាប់ភាពធន់នឹងអាកាសធាតុ រួមជាមួយនឹងក្រុមប្រឹក្សាជាតិភាសាខ្មែរ បានជួបប្រជុំទៀងទាត់រៀងរាល់សប្តាហ៍ ដើម្បីពិនិត្យបច្ចេកសព្ទប្រែប្រួលអាកាសធាតុតាមក្បួនភាសាខ្មែរ។ សទ្ទានុក្រមនេះគ្រោងនឹងធ្វើការបោះពុម្ពនៅឆ្នាំ២០១៧។ ទន្ទឹមគ្នានេះ លោកអ្នកអាចទទួលព័ត៌មានកាន់តែច្បាស់អំពី «ដំណើរការពិភាក្សាអំពីភាសា» នៅក្នុងលេខបន្ទាប់៕

## ឯកសារបោះពុម្ពផ្សាយនាពេលខាងមុខ



### ការលើកកម្ពស់ការចូលរួមចំណែករបស់វិស័យឯកជនក្នុងការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុនៅកម្ពុជា

ការសិក្សាលើការលើកកម្ពស់ការចូលរួមចំណែកពីវិស័យឯកជនឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុនៅកម្ពុជា ដែលបានរៀបរាប់នៅក្នុងអត្ថបទនៃទំព័រទី៣ បានកំណត់អំពីកម្មវិធី និងសកម្មភាពពាក់ព័ន្ធនានាដែលវិស័យឯកជនបានចូលរួមចំណែក និងបានវិភាគបញ្ហាប្រឈមដែលបានជួបប្រទះ។ របាយការណ៍នេះក៏បានបង្ហាញអំពីកាលានុវត្តភាព និងអនុសាសន៍សម្រាប់កៀគរវិស័យឯកជនសំដៅបង្កើនការចូលរួមរបស់ពួកគេ។ ការសិក្សានេះកំពុងស្នើសុំការអនុម័តពីអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព និងចេញផ្សាយក្នុងពេលឆាប់ៗនេះនៅលើគេហទំព័រនាយកដ្ឋានប្រែប្រួលអាកាសធាតុ www.camclimate.org.kh៕

## ព្រឹត្តិការណ៍សំខាន់ៗនាពេលខាងមុខ

- កក្កដា: កិច្ចប្រជុំពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធស្តីពីសូចនាករស្ទួលរបស់គម្រោងយុទ្ធសាស្ត្រសម្រាប់ភាពធន់នឹងអាកាសធាតុ(SPCR)
- កក្កដា: សិក្ខាសាលាស្តីពីការវិភាគបញ្ហាប្រឈម និងឱកាសសម្រាប់បន្សាំតាមបែបសហគមន៍នៅកម្ពុជា
- កក្កដា: ការប្រកាសអនុវត្តយន្តការគាំទ្រសង្គមស៊ីវិលសម្រាប់គម្រោងបន្សាំនឹងការប្រែប្រួលអាកាសធាតុ
- សីហា: សិក្ខាសាលាបណ្តុះបណ្តាលស្តីពីការវាយតម្លៃភាពងាយរងគ្រោះ និងការធ្វើផែនការបន្សាំនឹងការប្រែប្រួលអាកាសធាតុ, ខេត្តព្រៃវែង
- សីហា: សិក្ខាសាលាបណ្តុះបណ្តាលស្តីពីគោលការណ៍ណែនាំអនុវត្តមូលនិធិកម្មវិធីCCCA ទៅកាន់គម្រោងស្រាវជ្រាវនិងច្នៃប្រឌិត
- សីហា: កិច្ចប្រជុំលើកទីមួយរបស់ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព
- កញ្ញា: វគ្គបណ្តុះបណ្តាលស្តីពីការតាមដានទិន្នន័យមូលដ្ឋានជំនួយអភិវឌ្ឍន៍ផ្លូវការពាក់ព័ន្ធការប្រែប្រួលអាកាសធាតុ និងហិរញ្ញប្បទានប្រែប្រួលអាកាសធាតុទៅកាន់ដៃគូអភិវឌ្ឍន៍
- កញ្ញា: សិក្ខាសាលាបណ្តុះបណ្តាលស្តីពី ការវាយតម្លៃភាពងាយរងគ្រោះ និងការធ្វើផែនការបន្សាំនឹងការប្រែប្រួលអាកាសធាតុ, ខេត្តកំពង់ឆ្នាំង
- កញ្ញា: សិក្ខាសាលាបណ្តុះបណ្តាលស្តីពីការប្រែប្រួលអាកាសធាតុសម្រាប់យុវជននៅថ្នាក់ក្រោមជាតិ
- កញ្ញា: សិក្ខាសាលាលើកកម្ពស់ចំណេះដឹងស្តីពីការប្រែប្រួលអាកាសធាតុទៅកាន់និស្សិតសាកលវិទ្យាល័យ៕

*សម្រាប់ព័ត៌មានទាក់ទងនឹងឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុឬឯកសារបោះពុម្ពថ្មីៗ សូមតាមដានគេហទំព័រ www.camclimate.org.kh*

**គាំទ្រដោយ**

កម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា
CAMBODIA CLIMATE CHANGE ALLIANCE
Implemented by: Ministry of Environment
Supported by: European Union, UNDP, SWEDEN

**អាសយដ្ឋានទាក់ទង**

នាយកដ្ឋានប្រែប្រួលអាកាសធាតុ
អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព
ស្ថិតក្នុងក្រសួងបរិស្ថាន អគារមរតកតេជោ ជីឡូតិ៍លេខ៥០៣ ផ្លូវកៅស៊ូអមមាត់ទន្លេបាសាក់
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ
ទូរស័ព្ទ៖ (+៨៥៥-២៣) ៦៣១ ៨៣៧០ | សារអេឡិចត្រូនិក៖ admin@camclimate.org.kh
គេហទំព័រ៖ www.camclimate.org.kh